ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៦០៤
ចុះថ្ងៃទី ២៩-០៩-២០០៩
សាលដីកា
លេខ : ៥៣ "ក្រ.III.ស"
ចុះថ្ងៃទី ២៦-០៨-២០១១

តាមនាមប្រជារាស្ត្រខ្មែរ
សាលាឧទ្ធរណ៍ភ្នំពេញ
**********

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១១-០៨-២០១១ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៦០៤ ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០០៩ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted] ផេងស៊ុត ភេទប្រុស អាយុ ៤២ឆ្នាំ ជនជាតិថៃ មុខរបរលក់ខោអាវ កើតនៅឃុំអាំភើមឿង ស្រុកឈុំផុន ក្រុងថេប ប្រទេសថៃ ទីលំនៅសព្វថ្ងៃភូមិសុខ[redacted] ខេត្តថេប (ប្រទេសថៃ) ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] (លែងលះ) មានកូន ០២នាក់ ចាប់ខ្លួនថ្ងៃទី ២៥-១២-២០០៧ និងឃុំខ្លួនថ្ងៃទី ២៨-១២-២០០៧។

មានលោក [redacted]ចន្ថា ជាមេធាវីការពារ។

**ជាប់ចោទពីបទ: ជួញដូរគ្រឿងញៀន និងឆ្លងដែនខុសច្បាប់** ប្រព្រឹត្តនៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃច្បាប់អន្តោប្រវេសន៍។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣៩ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ផេងស៊ុត ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៦០ "គ" ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

## ឯដំណើររឿងមានដូចតទៅ:

កាលពីថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៧ វេលាម៉ោង បួន និងដប់នាទីទៀបភ្លឺ កំលាំងការិយាល័យប្រឆាំងគ្រឿងញៀន សហការជាមួយកំលាំងវរៈសេនាតូចនគរបាលការពារព្រំដែនលេខ ៩១១ បានចុះបង្រ្កាបជាក់ស្តែងករណីឆ្លងដែនខុសច្បាប់ និងជួញដូរគ្រឿងញៀនខុសច្បាប់នៅចំណុចជាប់របងកាស៊ីណូផ្កាយប្រាំ ភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ ដោយបានដកហូតវត្ថុតាង : ១-ថ្នាំគ្រាប់ (យ៉ាម៉ា) ដែលមានអក្សរ WY តែម្ខាងមានចំនួន ២០ ថង់ ពណ៌ខៀវ និង០៦ថង់ ពណ៌សថ្លា សរុបចំនួន ៥១៣៧ គ្រាប់ ស្មើនឹងទម្ងន់ ៤៨០ក្រាម ២-ម្សៅពណ៌ស (ICE) ចំនួន ០៣ថង់ ពណ៌សថ្លា មានទម្ងន់ ២៩០ក្រាម ៣-ទូរស័ព្ទដៃ ០១ (ម៉ាកសាមសុង) ៤-ប្រាក់បាតថៃ ១០០បាត និងឃាត់ខ្លួនមនុស្សចំនួន ០១នាក់ ជនជាតិថៃ។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៦០ "គ" ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

១- ផ្តន្ទាទោសឈ្មោះ [redacted] ផេងស៊ុត ភេទប្រុស អាយុ ៤៤ឆ្នាំ. ជនជាតិថៃ ដាក់ពន្ធនាគារកំណត់ ១៧ឆ្នាំ (ដប់ប្រាំពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួន ២៥ ខែធ្នូ ឆ្នាំ២០០៧ ពីបទ ជួញដូរគ្រឿងញៀន ប្រព្រឹត្តនៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៧ តាមមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២- នៅពេលសាលក្រមនេះចូលជាស្ថាពរ បង្គាប់ឱ្យឈ្មោ[redacted] ផេងស៊ុត បង់ប្រាក់ពិន័យចំនួន ៤០.០០០.០០០ រៀល "សែសិបលានរៀល" ចូលជាថវិការដ្ឋ ករណីគ្មានប្រាក់បង់សំណងធនទណ្ឌនោះទេ អនុញ្ញាតឱ្យចាប់ដាក់គុកបង្ខំរូបកាយ តាមមាត្រា ៥២៣ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

៣- វត្ថុតាងគ្រឿងញៀន មេតំហ្វេតាមីន ចំនួន ៥.១១៤ គ្រាប់ "ប្រាំពាន់មួយរយដប់បួនគ្រាប់" និងម្សៅពណ៌ស "ខេទីតកក" ចំនួន ០៣កញ្ចប់ "បីកញ្ចប់" ត្រូវរឹបអូស និងបំផ្លាញចោល។

៤- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ផេងស៊ុត. មេធាវី. អ្នកបកប្រែភាសាខ្មែរ-ថៃ និងចំពោះមុខបណ្តឹងអាជ្ញា បើកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣៩ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ផេងស៊ុត ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៦០ "គ" ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយជនជាប់ចោទឈ្មោះ [redacted] ផេងស៊ិត បានឆ្លើយនៅសាលាដំបូងខេត្តបន្ទាយមានជ័យ

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ការអានរបាយការណ៍របស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះ តំណាងមហាអយ្យការសុំតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦០ "គ" ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការដដែល ដោយមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ និងសុំឱ្យសម្រេចឡើងវិញពីការឆ្លងដែនខុសច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយពីបានស្តាប់របាយការណ៍ និងសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ខ្លួនសុំសំណូមពរ សុំឱ្យបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួន យោងតាមមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ ។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់ ។

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា៖

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៩ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ផេងស៊ិត ធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- តាមចម្លើយសារភាពរបស់ខ្លួន ជនជាប់ចោទបានបញ្ជាក់ថា កាលពីថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០០៧ ខ្លួនចេញពីក្រុងថេប មកផ្សាររោងគ្លឿ រួចលួចចូលដីខ្មែរ ហើយមកស្នាក់នៅបន្ទប់លេខ ៩៣១៩ នៃសណ្ឋាគារហ្គាដិន, រយៈពេលនោះខ្លួនបានទទួលថ្នាំពីបុរសម្នាក់ចំនួន ៧ (ប្រាំពីរ) ដុំនៅថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៧ និងថា ខ្លួនបានទទួលយកកាបូបខ្មៅពីស្រីថៃម្នាក់ ក្នុងកាបូបនោះស្រីនោះថា ជាថ្នាំខ្មែរយកទៅលក់នៅក្រុងថេប តែតាមពិតថ្នាំនៅក្នុងកាបូបនោះដែលសមត្ថកិច្ចឆែកចាប់បាននៅនឹងខ្លួនរបស់ខ្លួន គឺជាថ្នាំញៀនមែន ។ ខ្លួនត្រូវបានស្រីថៃជួលក្នុងតម្លៃ ៣.០០០បាត ឱ្យមកយកថ្នាំញៀនពីស្រីខ្មែរយកទៅលក់នៅក្រុងថេប ។ សមត្ថកិច្ចចាប់ឃាត់ខ្លួន និងឆែកចាប់រឹបអូសថ្នាំញៀនបានពីខ្លួន ក្រោយពេលដែលខ្លួនបានទទួលថ្នាំញៀនគ្រប់ចំនួន និងបម្រុងលួចចេញទៅប្រទេសថៃវិញ តាមច្រករបៀង ។

- ដូច្នេះ រាល់ការឆ្លើយបដិសេធផ្សេងៗរបស់ជនជាប់ចោទ គឺគ្រាន់តែជាការដោះសាផ្ទុយពីការពិត ដើម្បីគេចវេសពីការទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួន ចំពោះមុខច្បាប់ប៉ុណ្ណោះ ។

៣- ជនជាប់ចោទបានលួចឆ្លងចូលព្រំដែននៃប្រទេសកម្ពុជាដោយខុសច្បាប់ ហើយ និងប្រព្រឹត្តអំពើជួញដូរគ្រឿងញៀនខុសច្បាប់ ។

- តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៦៤០ ដសស ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០០៧, ដីកាសន្និដ្ឋានស្ថាពរលេខ ២០៦៣ ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០០៨ និងដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៦៧ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៨ របស់អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ សម្រេចចោទប្រកាន់ និងឱ្យជំនុំជម្រះលើជនជាប់ចោទ ពីបទ ជួញដូរគ្រឿងញៀន និងឆ្លងដែនខុសច្បាប់ តែសាលាដំបូងខេត្តបន្ទាយមានជ័យសម្រេចផ្តន្ទាទោសលើជនជាប់ចោទ តែពីបទ ជួញដូរគ្រឿងញៀនប៉ុណ្ណោះ ហេតុនេះ គួរពិចារណាឡើងវិញ តាមមាត្រា ៣៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤- មានពិរុទ្ធលើជនជាប់ចោទ ជួញដូរគ្រឿងញៀន និងឆ្លងដែនខុសច្បាប់ ប្រព្រឹត្តនៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៧ បទល្មើសមានថែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃច្បាប់ស្តីពីអន្តោប្រវេសន៍ ។

៥- សាលក្រមព្រហ្មទណ្ឌលេខ ៦០ "គ" ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យសម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែចំណុចទី ១ ត្រូវបដិសេធចោល ហើយសម្រេចឡើងវិញ ដូចយល់ឃើញខាងលើ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៩ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ផេងស៊ុត ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦០ "គ" ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការ លើកលែងតែចំណុចទី ១ ត្រូវបដិសេធចោល ហើយសម្រេចឡើងវិញថា: "ផ្តន្ទាទោសឈ្មោះ [redacted] **ផេងស៊ុត ហៅ ស៊ីត** ភេទប្រុស អាយុ ៤៤ឆ្នាំ ជាតិថៃ ដាក់ពន្ធនាគារកំណត់ ១៧ (ដប់ប្រាំពីរ) ឆ្នាំ ពីបទ ជួញដូរគ្រឿងញៀន និង ៦ខែ (ប្រាំមួយខែ) ពីបទ ឆ្លងដែនខុសច្បាប់ ប្រព្រឹត្តនៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៧ និងត្រូវបណ្តេញចេញពីប្រទេសកម្ពុជាក្នុងរយៈពេល០១សប្តាហ៍ ក្រោយពីជននេះបានអនុវត្តទណ្ឌកម្មចប់សព្វគ្រប់តាមមាត្រា ៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃច្បាប់ស្តីពីអន្តោប្រវេសន៍" ក្រៅពីនេះទុកនៅដដែល ។

តាមមាត្រា ៣៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ✍

៣- បង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១១ ប្រកាសជាសាធារណៈនៅថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១១ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

យូ ប៊ុនឡេង

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៤
ក្រឡាបញ្ជី